# សម្ភាសន៍ជាមួយ នឹម កុន ភេទស្រី អាយុ៤៤

## មុខងារសម័យខ្មែរក្រហមៈ“ប្រជាជន”

ស្រុកកំណើតកើតនៅភូមិតាពៅ ឃុំ.......... ស្រុកបារាយណ៍ ខេត្តកំពង់ធំ

សព្វថ្ងៃរស់ ភូមិទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣

សម្ភាសន៍ដោយៈ ឌី ខាំបូលី

០០:៣៦ :៥០

២១ ទំព័រ

បូលីៈ មីងឈ្មោះអីមីង?

កុនៈ កុន!

បូលីៈ ត្រកូលអីទៅ?

កុនៈ នឹម!

បូលីៈ នឹម កុន?

កុនៈ ចា៎ស!

បូលីៈ មីងអាយុប៉ុន្មានហើយ?

កុនៈ ៤៤ ។

បូលីៈ ចឹងកាសម័យខ្មែរក្រហម មីង៧៥ហ្នឹង អាយុប៉ុន្មានមីងកាលហ្នឹង?

កុនៈ មិនដឹងប៉ុន្មានទេ ភ្លេចអស់ហើយ?

បូលីៈ នៅក្មេងទេ?

កុនៈ ២០ជាងហើយ!

បូលីៈ ទេ! ២០ជាងណា ។ ឥលូវទើប៤៤ហ្នឹង ។

កុនៈ មិនដឹងប៉ុន្មានទេ?

បូលីៈ កាលពីមុននៅក្មេង! ហើយមីងមានស្រុកកំណើតនៅឯណាដែរ កើត?

កុនៈ ស្រុកខ្ញុំកើតនៅ តាពៅ ។

បូលីៈ នៅឯណាវិញ?

កុនៈ នៅតាពៅ ។ តាពៅយើងជិតក្រវ៉ា អាយើងកំពង់ថ្មនេះ ។

បូលីៈ ហ៊ូ! មីងនៅកំពង់ធំ?

កុនៈ ចា៎ស! ខេត្តកំពង់ធំ ។

បូលីៈ ស្រុកអីគេ?

កុនៈ ភូមិតាពៅតែម្តង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

បូលីៈ មីងមានបងប្អូនប៉ុន្មាននាក់?

កុនៈ ៤នាក់ ។

បូលីៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

កុនៈ ស្រីទាំងអស់ ។

បូលីៈ ឥលូវនៅរស់ប៉ុន្មានឥលូវ?

កុនៈ នៅរស់ទាំងអស់ ។

បូលីៈ នៅរស់ទាំងអស់ដែរណ៎?

កុនៈ ចា៎ស!

បូលីៈ ឪពុកម្តាយមីង អ្នកកំពង់ធំដែរ?

កុនៈ ចា៎ស!

បូលីៈ គាត់នៅរស់ទេឥលូវ?

កុនៈ នៅ!

បូលីៈ នៅទាំងពីរនាក់?

កុនៈ នៅទាំងពីរនាក់ ។

បូលីៈ អាយុវែងៗហើយណ៎! ហើយពូឈ្មោះយាុំ! អីគេយាុំ?

កុនៈ ហួន យាុំ ។

បូលីៈ ហួន យាុំនែ៎ក! គាត់អាយុប៉ុន្មានហើយពូឥលូវ?

កុនៈ គាត់ឥលូវ ៥០ហើយដឹង ។

បូលីៈ ៤៩ ។ ឆ្នាំខ្មែរ គិតមិនចេញ ឆ្នាំបារាំងទៅស្រួលខ្ញុំបូកដក ។ ហើយកូនទាំងអស់ប៉ុន្មានមីង?

កុនៈ ៦ ។

បូលីៈ ៦ហេ៎! ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

កុនៈ ស្រី៤ ប្រុស២ ។

បូលីៈ ស្រី៤ ប្រុស២ ។

កុនៈ ខ្សត់ប្រុសជាងគេ?

បូលីៈ ទី១ ឈ្មោះអីគេ?

កុនៈ មួន សាម៉ុន ។

បូលីៈ ហ្នឹងស្រី ឬក៏ប្រុសមីង?

កុនៈ ស្រី ។

បូលីៈ អាយុប៉ុន្មានហើយស្រី?

កុនៈ ២៣ ចូល២៤ ហើយ ។

បូលីៈ ចុះទី២?

កុនៈ ចុះទី២! មូនសាម៉េន ។

បូលីៈ ស្រីប្រុស អាហ្នឹង?

កុនៈ ស្រី ។

បូលីៈ ហ៊ូ! នេះសាម៉េន សាម៉េន អង្គុយឲ្យចំមុខ ។ សាម៉េន អាយុប៉ុន្មានហើយនេះ?

កុនៈ ៩៣ ។

បូលីៈ ចុះទី៣?

កុនៈ ទី៣ មុន យៀន ។

បូលីៈ មុន យៀន ។

កុនៈ ប្រុស ។

បូលីៈ អាយុប៉ុន្មាន?

កុនៈ ១៧ ។

បូលីៈ ទី៤ ឈ្មោះអីគេ?

កុនៈ ប៊ុន យ៉ាន ។

បូលីៈ ប៊ុន យ៉ាន ។ ប្រុសដែរ?

កុនៈ ប្រុស ។

បូលីៈ មួយ យាន មួយយ៉ាន?

កុនៈ ចាស!

បូលីៈ អាយុប៉ុន្មានហើយយ៉ាន?

កុនៈ ១៣ ។

បូលីៈ ទី៥?

កុនៈ ប៊ុន សម័យ ។

បូលីៈ ប៊ុន សម័យ! នេះហ៎! ស្រី?

កុនៈ ស្រី?

បូលីៈ អាយុប៉ុន្មានហើយសម័យ?

កុនៈ ១២ មិនដឹង ។ ១១!

បូលីៈ ១១! មីង ២ ទៅពាឆ្នាំ១ ។

កុនៈ ពាឆ្នាំ២ ។

បូលីៈ ពាឆ្នាំ ២! ទី មុន ចាន់ធូ ហៅក្រៅអីគេ ហៅក្រៅ?

កុនៈ កាតុ ។

បូលីៈ ចាន់ធូ ហៅកាតុ! អាយុប៉ុន្មានហើយ កាតុ?

តុៈ ៩ ។

បូលីៈ ៩ហើយ ។

កុនៈ ដឹងអាយុខ្លួនឯង ច្បាស់តែម្តង ។

បូលីៈ ហើយ សាម៉ុន មានគ្រួសារហើយ! បានកូនប៉ុន្មានហើយ?

កុនៈ ១!

បូលីៈ ធ្វើអីសាម៉ុនឥលូវ?

កុនៈ មានធ្វើអីទេ! ប្តីធ្វើទាហាន ។

បូលីៈ ទាហាន! ទាហានព្រះវិហារ ហើយន៎?

កុនៈ ចា៎ស!

បូលីៈ ហើយសាម៉េន នៅទេ?

កុនៈ នៅលីវ ។

បូលីៈ សាម៉េន ទៅធ្វើការនៅកូរ៉េប៉ុន្មានឆ្នាំ?

កុនៈ ៣ ។

បូលីៈ ហើយហត់ទេ ទៅធ្វើការនៅហ្នឹង?

កុនៈ ហត់ដែរ ។

បូលីៈ ហើយ ពិបាក ស្រួលយ៉ាងម៉េចខ្លះ បើប្រៀបធៀបធ្វើការស្រុកយើង?

កុនៈ ពិបាកស្រួលជាមួយគ្នា ។

បូលីៈ យ៉ាងម៉េចទៅប្រាប់បានទេ? អាចរៀបរាប់បានទេ រៀបរាប់ស្រួល ពិបាកយ៉ាងម៉េចនៅស្រុកគេ?

មុនៈ ប៉ះចំអាថៅកែ ស្រួលគេចិត្តល្អចឹងទៅ បើប៉ះចំថៅកែពិបាក ស្ដីបន្ទោសយើងចឹងទៅ ធ្វើអីត្រូវក៏ខុសរហូត ។

បូលីៈ យើងទៅធ្វើហ្នឹង ទៅធ្វើខាងអី?

មុនៈ ដេរវាំងននៗ

បូលីៈ ចឹងចេះដេរស្អាត់ហើយចឹង?

មុនៈ ចេះដេរស្អាត់តា ។ ហើយធ្វើម៉េច បានយើង បានទៅ?

មុនៈ ម៉ែឲ្យទៅមួយសារហ្នឹង ។

បូលីៈ ដាក់ពាក្យម៉េច អីម៉េច បានៗទៅ?

មុនៈ ដាក់ពាក្យទៅ! ដាក់ពាក្យ១ខែ បានៗ ។

បូលីៈ ទៅខាងភ្នំពេញ?

មុនៈ ចា៎ស!

បូលីៈ ហើយ ដល់ពេលនៅហ្នឹង នៅយ៉ាងនៅយ៉ាងម៉េចទៅ ផ្ទះអីយ៉ាងម៉េចទៅ? ជួលផ្ទះគេយ៉ាងម៉េចទៅ?

មុនៈ និយាយរួមទៅ ថៅកែវិញ ផ្ទះហ្នឹងគេរៀបដូជជាខុនដូរចឹងណា ផ្ទះគេប៉ុន្តែគេ ផ្ទះគេវាបន្ទប់គ្រប់បន្ទប់ចឹងទៅសម្រាប់កូនគេ ។

បូលីៈ ម្នាក់មួយបន្ទប់ចឹងទៅ?

មុនៈ ចាស៎!

បូលីៈ យើងទៅដល់ស្គាល់ខ្មែរៗយើងច្រើនទេ?

មុនៈ អត់មានខ្មែរទេ! ខ្ញុំដេរនៅក្នុងផ្ទះគេដូចថៅកែយកអីវ៉ាន់ មកដេរក្នុងផ្ទះផ្សេង ។

បូលីៈ ចឹងអារោងចក្រដែលខ្មែរយើង ទៅរាប់ពាន់នោះអត់ទេ?

មុនៈ អត់ទេ! បើសិននៅក្នុងរោងចក្រ ចឹងប្រហែលស្រួល ប៉ុន្តែនេះថៅកែយកទៅ តាមផ្ទះ ។ និយាយរួមទៅ ធ្វើការតាមផ្ទះផង និងដេរវាំងននផងឲ្យគេ នៅកន្លែងច្រើន ។

បូលីៈ ហើយគេឲ្យប្រាក់ប៉ុន្មានទៅ?

មុនៈ មួយខែ២០០ ។

បូលីៈ មួយខែ២០០?

មុនៈ ចាស!

បូលីៈ អ្នកខ្លះគេទៅធ្វើការបានរោងចក្រ បានមួយខែជិត១០០០ អីណានោះ?

មុនៈ អានោះរោងចក្រ អានេះតាមផ្ទះ ៗ និយាយរួមទៅយើងដាក់ពាក្យទៅខាងមេកផ្ទះ បានមេផ្ទះចឹងទៅ ដូចថាមេផ្ទះដែរ តែមិនសូវខាងដាំស្ល ៗ ដល់ចឹងទៅបាន!

បូលីៈ ចុះយ៉ាន ធ្វើអីអីយ៉ាន? រៀនថ្នាក់ទីប៉ុន្មានហើយយ៉ាន?

កុនៈ ហ៊ឹម! អត់រៀនផងឥឡូវ ៗ

បូលីៈ យ៉ានអត់រៀនទេ! ចុះយិន?

កុនៈ យិនក៏អត់រៀនដែរ ៗ

បូលីៈ យិនក៏អត់រៀនដែរ ៗ ថ្នាក់ទី២ឈប់? ម៉េចចឹងបានជាឆាប់ឲ្យឈប់ម៉្លេះ?

កុនៈ វាអត់ចង់រៀន វាអត់ចង់រៀនតែម្ដង ៗ ចូលរៀនបានត្រឹមថ្នាក់ទី ២ ទី៣ ក៏ឈប់រៀនអស់រលីង មិនដឹងធ្វើម៉េចវា ដេញវាទៅ វាមិនទៅ ៗ ឥឡូវចូលក្បួន២នាក់ទៀតហើយ ៗ

បូលីៈ ម៉េចទៅក្បួនម៉េច?

កុនៈ អត់ចង់ទៅរៀនផង ៗ ចាំមើលថ្ងៃមិនដឹងទៅ ដឹងអត់ផង ៗ

បូលីៈ ហ៊ូ! ចាន់ធួងងតែអត់ទៅរៀន អត់បានទៅធ្វើការនៅភ្នំពេញទៅណា ៗ

កុនៈ ឲ្យទៅរៀនមិនទៅ ៗ

បូលីៈ ចាន់ធួ ចង់ធ្វើការអត់? ឬក៏ចង់នៅធ្វើ ៗ

កុនៈ អត់ចង់រៀនទេ! ចង់ធ្វើស្រែវិញ មើលទៅ មិនដឹងថាធ្វើស្រែវាលំបាកអត់ទេ ៗ

បូលីៈ ខំរៀន បានបានធ្វើការ ៗ សម័យថ្នាក់ទីប៉ុន្មាន?

សម័យៈ ទី៥ ៗ

បូលីៈ បានទី៥ដែរ ៗ ចាន់ធួទី៣ទេណ៎! ចាន់ធួងងប្រឹងរៀនឲ្យដល់បាក់ឌុបណាស់!

កុនៈ ខ្ញុំថាខំប្រឹងឲ្យវារៀនបានខ្ពស់ជាងខ្ញុំ ដល់ពេលវាលេងផងអីផងទៅរៀន ៗ

បូលីៈ ឥឡូវនាំគ្នាជួយ រុញមើលក្រែងលោបានបាក់ឌុបអីចឹងទៅក្រែងបានធ្វើការ ធ្វើការអីហ្នឹងគេ ៗ

កុនៈ រុញទៅដែរ តែវាមិនទៅ មិនដឹងធ្វើយ៉ាងម៉េចវាទេ ឲ្យវាទៅ!

បូលីៈ ចុះមីងមានដែលទៅលេងកំពង់ធំស្រុកកំណើតទេ?

កុនៈ ម្ដងដែរ ៗ

បូលីៈ ប៉ុន្មានឆ្នាំហើយបានទៅលេងម្ដង?

កុនៈ ទៅផ្ដាច់ខ្លួនបានទៅម្ដង ៗ

បូលីៈ ហ្ហ៎ូ! ផ្តាច់ខ្លួន ហើយបានៗទៅ ។
កុនៈ ទើបតែទៅ ប៉ុន្មាន ២ទៅ៣ឆ្នាំហើយហ្នឹង ។
បូលីៈ ចឹងទេ?
កុនៈ ផ្តាច់ខ្លួនមកទើបបានទៅ មិនប៉ុន្មានឆ្នាំទេ ។
បូលីៈ ចុះមុនហ្នឹងបងប្អូននៅស្រុកកំណើត មានបានដឹងដំណឹងពីមីងទេ?
កុនៈ ដឹងតា!
បូលីៈ ដឹងតែនៅរស់អីចឹង?
កុនៈ ចា៎ស! គាត់មកនៅ គាត់នៅនេះតា ។
បូលីៈ នរណា?
កុនៈ ម៉ែឪខ្ញុំ ។
បូលីៈ អ្ហូ! នៅនេះទេចឹង?
កុនៈ ចា៎ស!
បូលីៈ នៅឯណាឥលូវ?
កុនៈ ផ្ទះគាត់នៅត្បូង ។
បូលីៈ គាត់មកនៅតាំងពីកាល?
កុនៈ គាត់មកនៅប្រហែលជា១០ឆ្នាំ! តាំពីកូនខ្ញុំនៅតូច ។
បូលីៈ ម៉េចបានគាត់សម្រេចចិត្តមកនៅនេះ?
កុនៈ គាត់ខ្ជិល នៅនោះវាលំបាក ។ នៅនេះជុំកូនជុំចៅ ។
បូលីៈ ហ៊ុមម្យ៉ាងដែរ ។ ហើយមីងចេញពី ស្រុកពីភូមិមកហ្នឹងតាំងពីឆ្នាំណាវិញ?
កុនៈ តាំងពី៨៦ ។
បូលីៈ ៨៦?
កុនៈ ចា៎ស!
បូលីៈ ចុះសម័យខ្មែរក្រហម មីងនៅជាមួយពីណា?
កុនៈ នៅជាមួយនេះហ្នឹង ។
បូលីៈ នៅឯណាទៅ?
កុនៈ នៅភ្នំ ។
បូលីៈ ពី៧៥-៧៩ណា ពេលខ្មែរក្រហមគ្រប់គ្រង?

កុនៈ ៧៩ ហើយ៧៩ ខ្ញុំនៅស្រុក ។

បូលីៈ នៅកំពង់ធំទេ?

កុនៈ ដល់៨៥,៨៦ បានខ្ញុំចូលព្រៃ ។

បូលីៈ យ៉ាងម៉េចបានមីងចូលព្រៃ?

កុនៈ កាលពីនៅវាមិនទាន់បានគិត ចេះតែតាមគេតាមឯង គេថាមកភ្នំសប្បាយ សប្បាយតាមគេទៅ ។

បូលីៈ ថាមកភ្នំសប្បាយ?ដល់មកសប្បាយទេ?

កុនៈ មានសប្បាយអីផង សប្បាយតែរឿងហូបចុកអីហ្នឹង ។

បូលីៈ ហូបចុកបរបូរ ។

កុនៈ សប្បាយស្លៀកពាក់អីគេបើឲ្យ ។

បូលីៈ ចុះសាមីនដឹងទេ ថាម៉ែចេញស្រុកពី៨៦អី មានដឹងទេ?

មីនៈ អត់ដឹងផង ។

បូលីៈ ទើបតែដឹងថ្ងៃហ្នឹង?

មីនៈ ទើបតែដឹងថ្ងៃនេះ ។

បូលីៈ បើសាមីនទំនេរ អង្គុយស្តាប់ទៅណា ។

មីនៈ ចា៎ស!

បូលីៈ បើអត់ទំនេរអាច ទៅធ្វើអីក៏ធ្វើទៅសិនទៅណាចុះ បើទំនេរស្តាប់ប្រវត្តិម៉ែតិចៗទៅចឹង ។ ចាន់ធូចឹងដែរ ដើម្បីឲ្យដឹងថាម៉ែឆ្លងកាត់អីខ្លះ ។ ហើយ៨៦ហ្នឹងមីង ចូលមកហ្នឹង ពីណានាំចូល?

កុនៈ គ្នាឯងនៅភូមិហ្នឹង ។ មកៗជាមួយតា០៥ ។

បូលីៈ ហ៊ូ! តា០៥ ទៅចុះទៅផ្ទាល់តែម្តង?

កុនៈ ចា៎ស! ទៅធ្វើការនៅមុខ(ស្តាប់ពុំបាន) ។

បូលីៈ ទៅធ្វើការនៅស្រុកបារាណ៍ហ្នឹង?

កុនៈ ចា៎ស!

បូលីៈ ប៉ុនអ្នកដែលនាំមីងមកនោះ តា០៥តែម្តង?

កុនៈ ទេ! និរសាគាត់ ។

បូលីៈ ឈ្មោះអីនិរសាគាត់?

កុនៈ ឈ្មោះអីទេ ភ្លេចបាត់ហើយ វាយូរហើយ ។

បូលីៈ នៅរស់ទេ?

កុនៈ ភ្លេចបាត់ហើយ ។

បូលីៈ ដែលគេចុះទៅហ្នឹង គេចុះទៅបន្ទុំយើង ឬក៏គេចុះទៅឃោសនា?

កុនៈ អត់ទេ! អត់បន្ទុំទេ ។ របៀបនិយាយថាយើងចង់មកលេង ព្រោះថាបងប្អូនមីងមានៅចឹងទៅ យើងចង់មក អត់មានពិបាកអីផង ។

បូលីៈ ហើយមកឪពុកម្ដាយមីងគាត់ថាម៉េច?

កុនៈ ម្ដាយខ្ញុំអត់ដឹងទេ ។

បូលីៈ ចុះម៉េចគគាត់មិននឹកស្លាប់ហើយចឹង ។

កុនៈ គាត់នឹកចេះតែនឹកហើយ បើវានៅឆ្ងាយពីគ្នា ពេលគេផ្ដាច់ខ្លួនក៏មកទៅ ។

បូលីៈ ពេលដែលមីងចូលមកគាត់ដឹងទេ?

កុនៈ អត់ដឹងផង!

បូលីៈ ចុះក្រោយមកទៀតគាត់ដឹងទេ?

កុនៈ ក្រោយមកទៀត បានគាត់ដឹង ។

បូលីៈ ពីណាទៅប្រាប់កាត់បានគាត់ដឹង?

កុនៈ ចុះអ្នកខ្មែរក្រហម ទៅគេស្គាល់គាត់ គេប្រាប់ទៅ ។

បូលីៈ ដល់ពេលគាត់ដឹង គាត់មានអារម្មណ៍យ៉ាងម៉េចដែរ?

កុនៈ ដឹងមានអារម្មណ៍យ៉ាងម៉េច បើខ្ញុំនៅឆ្ងាយ ។ មានអារម្មណ៍ថាកូនទៅរស់ក៏អរទៅ ។

បូលីៈ ហើយដល់ ពេលមីងចូលមកភ្នំចឹង ដូចថាយើងទំនាក់ទំនងជាមួយឪពុកម្ដាយយើងទាក់ទងតាមណាទៅ?

កុនៈ ទាក់ទងតាមតេអូ ។

បូលីៈ ហ៊ូ! ចឹងបានតអូដែរ ។ មិនមែនថាយើងដាច់ខ្សែរយៈសុទ្ធ តែម្ដងទេណ៎ ។

កុនៈ ចង់ជួប ក៏ទាក់ទងហ្នឹងគេទៅ គេឲ្យទៅក្នុងហ្នឹងគេទៅ ក៏ទៅហៅឪពុកម្ដាយ យើងហ្នឹង និយាយឆ្លងឆ្លើយគ្នា ។

បូលីៈ ដែលមកលើភ្នំ យើងមកនៅមុំណា?

កុនៈ លើកទី១ ខ្ញុំនៅនែ៎កដើមអំពិលដងទង់ ។ ដល់ផ្លាស់ពីដើមហ្នឹងទៅ ខ្ញុំទៅអូរចង្កក ។ ដល់ផ្លាស់ពីអូរចង្កកទៅ មកនៅនេះវិញ ។

បូលីៈ ផ្លាស់ពីអូរចង្កកទៅមកនៅដីខ្មែរវិញ?

កុនៈ ចា៎ស!

បូលីៈ នៅដង់ទង់ហេតុអីបានជាផ្លាស់មកនៅដីខ្មែរវិញ?

កុនៈ ចុះយើងត្រូវរួវគ្នាហើយ ។

បូលីៈ ដោយសារតែឃួនវាយ ដេញមក ប្តក៏យ៉ាងម៉េច បានជាមកចង់ក ពេលហ្នឹងរត់ ប្តក៏យ៉ាងម៉េច?

កុនៈ ទេ! ឡើងមកធម្មតា អត់មានរត់ទេ ។ ឡើងដឹកឥវ៉ាន់មក យកមកស្រុកខ្មែរយើង ។

បូលីៈ ហើយមីងការហ្នឹង ការនៅឯណា?

កុនៈ ខ្ញុំការនៅឯចង់ក ។

បូលីៈ ហ៊ូ! បានន័យថាផ្លាស់យកពីអំពិល មកអូរចង់កនេះវិញ?

កុនៈ ចា៎ស!

បូលីៈ ឆ្នាំប្រហែលប៉ុន្មាន មីងមានចាំទេ?

កុនៈ អត់ចាំទេ! អត់យកចិត្តទុកដាក់ផង ។

បូលីៈ បែកចង់៨០ហើយណ៎?

កុនៈ ខ្ទង់ប៉ុណ្ណឹងដឹង ។

បូលីៈ ឥលូវសាម៉ុន ២២ហើយណ៎? អាយុ២៣! កើតឆ្នាំ៩០ប៉ុន្មាន?

កុនៈ ៩៣ ។

បូលីៈ ៩៣! ចឹងមីងការ នៅលើភ្នំទេមីងហ៎?

កុនៈ ការនៅលើភ្នំ ។ ដូចជាការ៩១ ។

បូលីៈ ការ៩១ ទេចឹង ។ ហ៊ូ! ចឹង៩១ នៅលើភ្នំនៅឡើយទេចឹង អត់ទាន់ចុះមកទេ?

កុនៈ នៅ!

កូនកុនៈ ៩១អី! ៩១កំណើតសាម៉ុន ។

បូលីៈ សាម៉ុន៩៣!

កូនៈ ៩៣ខ្ញុំ ។

បូលីៈ ៩៣អូនឯង?

កូនៈ ចា៎ស!

បូលីៈ ចឹង៩២សាម៉ុន?

កូនៈ ចា៎ស!

បូលីៈ ៩១ ។ បើសាម៉ុន៩១ មីង មិនការ៨៩ ចន្លោះហ្នឹង ។ ការបានប៉ុន្មាន បានចុះមក ឬក៏ការហើយបានចុះមក?

កុនៈ ប៉ុន្មានខែដែរ!

បូលីៈ ឥលូវសាម៉ុន កើតនៅឯណា កើតនៅភ្នំ ឬកើតនៅក្រោម?

កុនៈ កើតនៅក្រោមនេះតា ។

បូលីៈ កើត៩១ហ៎?

កុនៈ មិនជា៩០ប៉ុន្មាន ប្រហែលជា៩១ ។

បូលីៈ ៩១! ចាំមើលខ្ញុំស្មានមើលណា បើសិនជាកើត៩១ សាម៉ុន កើតនៅក្រោម ចឹងមីងចុះមកមុនសាម៉ុនកើត ។

កុនៈ កាលខ្ញុំចុះមក ខ្ញុំអត់ទាន់មាននេះផង ។

បូលីៈ អត់ទាន់មានទេហ៎?

កុនៈ ចា៎ស!

បូលីៈ ហ៊ូ! ចុះមក៩០ហើយចឹង ។ ព្រោះឆ្នាំ៩០ តាម៉ុកវាយយកបានអន្លង់វែង ត្រពាំងប្រាសាទយើងណា ហើយក៏បញ្ជូនកម្លាំងមកខាងក្រោមនេះដែរ ។ ឆ្នាំ៩០ ពេលដែលមីងនៅលើភ្នំហ្នឹង មីងកងពលលេខប៉ុន្មានកាលហ្នឹង?

កុនៈ មិនដឹងជាកងពលលេខប៉ុន្មានទេ ភ្លេចបាត់ហើយ ។

បូលីៈ កងពលតាណា៎?

កុនៈ នៅរួមគ្នាទាំងអស់ ។

បូលីៈ នៅរួមគ្នា ប៉ុន្តែគេមានកងពលគេដែរ?

កុនៈ កងពលមើលតាថន ។

បូលីៈ តាថន?

កុនៈ ចា៎ស! យាយុំ ។

បូលីៈ មិនមែនកងពលតា០៥ទេណ៎?

កុនៈ មិនមែនទេ ខ្ញុំផ្លាស់ពីហ្នឹងហើយ ។

បូលីៈ ផ្លាស់ពី៨០១មក?

កុនៈ ចា៎ស! ផ្លាស់ពីតា០៥ហ្នឹងមក ខ្ញុំមកនៅ ។

បូលីៈ ៨១៧?

កុនៈ តាថន មិនដឹងជាកងពលកាត់លេខប៉ុន្មាន ភ្លេចបាត់ហើយយូរហើយ ។

បូលីៈ ភ្លេចហើយ ។ កាលពេលគេចុះមក គេចុះមកតាមច្រកណា?

កុនៈ តាមច្រកជាំយើង ។

បូលីៈ មិនមែនឈូករុននេះទេ?

កុនៈ អត់ទេ! ជាំខាងអន្លង់វែង ។

បូលីៈ ជិះអីចុះមក?

កុនៈ ឡាន ។

បូលីៈ ធំៗណាណ៎?

កុនៈ ចា៎ស!

បូលីៈ កាលហ្នឹងពូមកជាមួយមីងដែរ ឬ?

កុនៈ មកទាំងអស់គ្នា ។

បូលីៈ ពូ គាត់ពិការឆ្នាំណា?

កុនៈ ដឹងគាត់ពិការឆ្នាំប៉ុន្មានទេ ខ្ញុំយកគ្នានោះ គាត់ពិការ ។

បូលីៈ ពេល(ស្តាប់ពុំបាន)មីងការហើយ?

កុនៈ ខ្ញុំការហើយ ។

បូលីៈ ពិការហើយ បានយកគ្នា? ហើយដឹងតែគាត់ពិការហើយមីងនៅទៅយកលគាត់ទៀត ឬយ៉ាងម៉េច?

កុនៈ ដូចថាបងគាត់ និងមីងខ្ញុំប្រាក់គ្នា ។

បូលីៈ ហើយនិងមីងរបស់មីង ត្រូវជាមិត្តភក្តិគ្នា?

កុនៈ ចា៎ស!

បូលីៈ បងគាត់មួយណា?

កុនៈ បងគាត់ខ្មោចនែ៎ក!

បូលីៈ បង្កើត ។

កុនៈ បងតាយ៉ាំ ។ គាត់ស្លាប់នៅអូរគ្រាវ ។

បូលីៈ ស្លាប់ដោយសារអី?

កុនៈ ប្រុស! នៅតែប្រពន្ធគាត់ ។

បូលីៈ គាត់ស្លាប់ដោយសារអី? ប្រពន្ធគាត់នៅទេ?

កុនៈ ប្រពន្ធគាត់ស្លាប់ហើយ ស្លាប់ទាំងប្ដី ទាំងប្រពន្ធ ។

បូលីៈ មូលហេតុអ្វី?

កុនៈ ឈឺ! ថាកើតទាច ។ ប្រពន្ធក៏កើត ទាច ប្ដីក៏កើតទាច ។

បូលីៈ កើតរោគថ្មើមហើយតាមមើល ។

កុនៈ ដល់ពេលនៅកូន១រាល់ថ្ងៃហ្នឹង ជាមួយអីតី ឥលូវ(ស្ដាប់ពុំបាន) បាត់ហើយ ។

បូលីៈ ជួនកាលយើង វាអត់មានអនាម័យអី មានពេទ្យអីណាព្យាបាលត្រឹមត្រូវ?

កុនៈ ទេមានតា លោកគ្រូ!

បូលីៈ មានដែរមីងន៎?

កុនៈ ចា៎ស!

បូលីៈ ពេទ្យគេ មន្ទីរពេទ្យបាលគេ រៀបធ្វើពីអី ឈើ ឬយ៉ាងមេច?

កុនៈ ឈើ!

បូលីៈ ធំប៉ុណ្ណាមីង?

កុនៈ ធំដែលហ្នឹងលោកគ្រូ ពេទ្យគេ កម្លាំងរាប់រយនាក់ ដេកឡើងល្វីងល្វើយដែរ ។ ឡើងដាក់ជំងឺ!

បូលីៈ គេហៅពេទ្យអីគេដែរ?

កុនៈ ពេទ្យខ្មែរក្រហម?

បូលីៈ ពេទ្យខ្មែរក្រហម ។

កុនៈ យើងនៅហ្នឹង ពេទ្យខ្មែរក្រហម ។

បូលីៈ ពេទ្យ១០០៣ ពេទ្យអីគេ?

កុនៈ ពេទ្យ១០០៣ ។

បូលីៈ ទៅចង្អក ហើយផ្ទះមីងនៅចង្អកនោះប៉ុណ្ណា?

កុនៈ ផ្ទះខ្ញុំប៉ុណ្ណេះដែរ ។

បូលីៈ ប៉ុណ្ណេះដែរ?

កុនៈ ចា៎ស!

បូលីៈ អ៎ធំម្ល៉េះ!

កុនៈ ប៉ុណ្ណេះឯង មីងអ្នកធ្វើ ។

អ្នកជិតខាងៈ កូនគាត់ច្រើន ធ្វើធំ ។

បូលីៈ ចង្អកនៅដីថៃ?

កុនៈ នៅជីថៃ(និយាយជាមួយកូន) ។

បូលីៈ ចឹងមីង១នៅជាមួយគ្នាដែរ?

កុនៈ ចា៎ស!

បូលីៈ នៅជុំគ្នា!ដល់ពេលការហើយនៅជុំគ្នាទៀត?

កុនៈ យើងនៅជាមួយគាត់ប៉ុន្មានខែបានបែក ។

បូលីៈ បែកផ្ទះ ។

កុនៈ ចេញមកបែកផ្ទះគ្នា ។

បូលីៈ ពេលចុះមក មកនៅឯណា នៅឯក្រោម?

កុនៈ ចុះមកដំបូងនៅឯ អូរជីក!

បូលីៈ កន្លែងផ្ទះតាម៉ុកហ្នឹង ។

កុនៈ អូរជីកនៅលើ ។

បូលីៈ អូរជីក! នៅត្រពាំងប្រាសាទយើងនៅ ។

កុនៈ ម៉ុំ៩៧ ។

បូលីៈ ម៉ុំអូរជីក ៩៧ ។

កុនៈ តំបន់១០៥ យើងហ្នឹង ។

បូលីៈ ហ៎ូ!១០៥ យើងនេះ?

កុនៈ ចា៎ស!

បូលីៈ អូរជីក ១០៥យើងនេះ ។ ហ៎ូ! នៅផ្លូវចឹង?

កុនៈ មិនមែនផ្លូវទេ ដូចឆ្ងាយដែរ ។

បូលីៈ បាទ! ប៉ុន្តែនៅក្នុងភូមិផ្លូវ ។ ហើយដល់ពេលនៅអូរជីកហ្នឹងយើង នៅផ្ដុំតាមកងពលយើង ឬក៏នៅលាយគ្នា?

កុនៈ នៅតាមកងពល ។

បូលីៈ កងពលនោះវាមានកងពល១០៥ វាមាន៩២០?

កុនៈ ចា៎ស!

បូលីៈ មីងមួយណាមីង?

កុនៈ ខ្ញុំនៅ៩២០ ។

បូលីៈ តា០៦ចឹងនោះ?

កុនៈ ចា៎ស!

បូលីៈ ពេលចុះមកដំបូងម៉េចទៅមីង ដូចថាកាត់ព្រៃរាគដីរាគអី ធ្វើផ្ទះធ្វើសម្បែងយ៉ាងម៉េចកើត មីងអាចរៀបរាប់បានទេ?

កុនៈ កាប់ឈើយើងសសរមូល ឈើមូលហ្នឹងធ្វើផ្ទះនៅ ។

បូលីៈ ពីរនាក់ពូហ្នឹងទៅ?

កុនៈ ចា៎ស! អត់មានទេ អត់មានស្អីបរដឹកផង (ស្តាប់ពុំបាន) ធ្វើឲ្យតែមានតំរូវនៅ ។

បូលីៈ ឲ្យតែបាននៅសិនទៅ?

កុនៈ ឲ្យតែនៅបានសិនទៅ ។

បូលីៈ ចុះក្រែងពេលហ្នឹង គាម៉ុក ចែកឈើ ចែកអីឲ្យ?

កុនៈ អត់ទេ! ពេលគេមានលុយគេធ្វើ ធ្វើស្អីចឹងទៅ បើយើងខ្វះខាតអី ឈើធម្មតាធ្វើកន្លែងជ្រកទៅ ។

បូលីៈ ហើយបាយម្ហូបអី អង្ករត្រីសាច់អី នរណាអ្នកឲ្យ?

កុនៈ រកខ្លួនឯង ។

បូលីៈ តែអត់ទាន់ចែកទេណ៎?

កុនៈ គេចែកដែរ ចែកដូចជាត្រីខកំប៉ុង ថ្ងៃណាគេនឹកឃើញគេឲ្យទៅ ថ្ងៃណាគេមិននឹកឃើញគេអត់ទៅ ។ ប៉ុនបានតិចតួច ១ ទៅ២ពេលអស់បាត់ហើយ ។

បូលីៈ ប៉ុនខាងអន្ទង់វែង មើលទៅចែកសម្បើមណាស់?

កុនៈ គេនៅជិត តែខ្ញុំនៅដាច់ស្រយាល ។

បូលីៈ តែពេលហ្នឹង ពូពិការហើយៗ?

កុនៈ គាត់ពិការ គាត់យកខ្ញុំ គាត់ពិការ ។

បូលីៈ ចឹងកសាងផ្ទះសំបែងអីក៏យ៉ាប់ដែរណា?

កុនៈ យ៉ាប់ ។

បូលីៈ នៅបានប៉ុន្មានឆ្នាំ បានមីងដូរមកនេះវិញ?

កុនៈ នៅបានយូរដែរគា តាំងពីកូនខ្ញុំមីបង ១ខួប ។

បូលីៈ សាម៉ុន?

កុនៈ ចា៎ស!

បូលីៈ សាម៉េន កើតនៅឯណា កើតនៅ?

កុនៈ កើតនៅទំនប់ដាច់ ។

បូលីៈ ហ៊ូ! ចឹងនៅនោះបាមកូន១?

កុនៈ ចាស!

បូលីៈ សាម៉ុន ហើយបានមកនៅនេះបានកូន៥ទៀត ។ ចឹងនៅបាន២ ទៅ៣ឆ្នាំទៀតយ៉ាងម៉េច?

កុនៈ បាទ! ២ឆ្នាំ ទៅ៣ឆ្នាំ នៅឯជិត១០៥ នៅបានជិត២ទៅ៣ឆ្នាំ បានមកនៅឯនេះខ្លះ ។

បូលីៈ មកនៅទំនប់ដាច់យើងមក ។ ម៉េច បានគេផ្លាស់មកទំនប់ដាច់នេះវិញ?

កុនៈ គេជូរកន្លែង ពី៤២០ មកនៅឯនេះវិញ ។

បូលីៈ ចឹង?

កុនៈ ចាស!

បូលីៈ ហ៊ូ! នេះមីងនៅនេះ ហើយនេះ ។

កុនៈ បើយើងមើលតាមដែនទី មីងនៅនេះ ម្តុំនេះអូរជីក ។

បូលីៈ ហូរជីកផ្លាស់ពីនេះ មកនេះ មកខាងកើតណា មកទំនប់ដាច់នេះ ។ អានេះគេហៅទួលប្រាសាទ?

កុនៈ ចាស!

បូលីៈ ទួលប្រាសាទនេះ អានេះទួលចារទេ ។ ម្តុំណាទួលប្រាសាទ? ឈើទាល សែនសុខ សែនល្អ ទួលពង្រ គោកចារ ។ ក្នុងនេះវាអត់ទាន់ ធ្វើថ្មីទេ វាតាមពិត ទៅខ្លះទួលប្រាសាទនេះ ដែនទីធ្វើចាស់ មានទួលពង្រទេមីង?

កុនៈ មានតា ។

បូលីៈ ទួលពង្រនៅខាងនោះ?

កុនៈ នេះ! នៅជាប់ទំនប់ ។

បូលីៈ នេះទួលពង្រហើយនេះ ។

កុនៈ សែនសុខ មានតែខ្លះទួលប្រាសាទ ។

បូលីៈ បាទ! ប្រាសាទសម្បូរមានទេ?

កុនៈ អត់ដឹងទេ!

បូលីៈ អត់ដែរដឹងទួលប្រាសាទនេះហើយចឹង ប្រាសាទសម្បូរនៅ ម្តុំគ្នាគេហ្នឹង ។ ហើយដល់ពេលមកនៅនេះផ្ទះមីងនៅអូរជីកនោះធ្វើយ៉ាងម៉េចវិញទៅ?

កុនៈ ផ្ទះហ្នឹងដល់ពេលនេះ ចោលផ្ទះតូចទៅ ។

បូលីៈ ឲ្យគេ?

កុនៈ មាននរណាគេយកផងហ្នឹងផ្ទះ ផ្ទះតូចដែរឈើ ។

បូលីៈ សព្វនៅទេផ្ទះហ្នឹង ។

កុនៈ ចោលអស់ហើយ កើតស្រែកើតអី ។ កើតស្រែ កើតចម្ការអស់ហើយ ។

បូលីៈ អ្នកស្រែចម្ការអស់ហើយ?

កុនៈ នៅដីទំនាប ។

បូលីៈ ចុះដីហ្នឹងយើងអត់ទៅចាប់វិញទេ?

កុនៈ អត់!

បូលីៈ គេចែកនេះ ។ ពេលមកនៅនេះ យើងនៅខាងក្រោមជាមួយ តា០៥?

កុនៈ ចាស!

បូលីៈ មីងដែលជួបគាត់ទេ តា០៥?

កុនៈ មិនដែលជួនឥលូវ ពីមុនជួបតា ។

បូលីៈ ទេ! ឥលូវគាត់ស្លាប់ហើយ ។

កុនៈ ស្លាប់ហើយ!

បូលីៈ កាលនៅពីអូរជីកមក?

កុនៈ ជួបតា០៥ តា០៦ ជួបទាំងអស់ ។

បូលីៈ គាត់យ៉ាងម៉េចដែរ តា០៥ ចរិតឬកពារអី?

កុនៈ អត់ទេ! គាត់ ។

បូលីៈ គាត់កាចទេ?

កុនៈ អត់កាចទេ! គាត់ស្លូត ។

បូលីៈ ហើយគាត់ដូចជាជាប់ជាមួយប្រជាជនទេ?

កុនៈ ចាស!

បូលីៈ ឬក៏គាត់មិនសូវជាមកនិយាយជាមួយប្រជាជនទេ?

កុនៈ បើជួបអ្នកស្គាល់ គាត់និយាយ(ស្តាប់ពុំបាន) ។

បូលីៈ គាត់មានផ្ទះមួយនៅទំនប់ដាច់នេះ?

កុនៈ មានតាផ្ទះគាត់ ផ្ទះគាត់តូចដែរ ។

បូលីៈ គេតាំងចម្ងាក់ តាំងអី ថ្ម?

កុនៈ ចា៎ស!

បូលីៈ ដែលទៅលេងផ្ទះគាត់ទេកាលហ្នឹង?

កុនៈ ខ្ញុំអត់ដែលទៅទេ គេអ្នកផ្សេងទៅហើយ ។ (ស្តាប់ពុំបាន) កូនគាត់អត់នៅ ។

បូលីៈ គេយក?

កុនៈ ចា៎ស! គេយក ។

បូលីៈ ខ្ញុំឃើញតា ពេលគាត់តាំងប្រាសាទ តាំងថ្មអី ។

កុនៈ មានតារូបចម្លាក់រូបអី ឥលូវ មិនដឹងទៅណាទៅណីអស់ហើយ ខ្ញុំមិនដែលចូល មិនដែរអីទេ ។

បូលីៈ ហើយដល់ពេលយើងមកនៅនេះ យើងប្រកបរបរ រកស៊ីអីយ៉ាងម៉េចទៅកាលជំនាន់ហ្នឹង?

កុនៈ ធ្វើស្រែ ។

បូលីៈ ធ្វើស្រែដដែរ ។ ហើយរបស់របរ គេចែកឲ្យទេ?

កុនៈ អត់!

បូលីៈ អត់មាននរណាគេចែកឲ្យទេចឹង?

កុនៈ អត់ទេ!

បូលីៈ ចឹងខុសគ្នា ខាងអន្លង់វែងគេចែកឲ្យសព្វគ្រប់?

កុនៈ គេចែកអីខ្លះ?

បូលីៈ ប្រេងកាត អង្ករ ស្ករស អំបិល ប៊ីចេង ក្រណាត់ ។

កុនៈ អត់មានចែកទេខ្ញុំនោះ ។

បូលីៈ ខាងនេះអត់តែម្តង? ពួកគេថាស្រលាញ់តាម៉ុកណាស់ ព្រោះតាម៉ុក ខ្វះខាតអីតាំងពីឈើធ្វើផ្ទះ ធ្វើសម្បែងចែកឲ្យទាំងអស់ ។

កុនៈ ពួកនោះនៅដាច់ពីតាម៉ុក?

បូលីៈ ខាងត្រពាំងប្រាសាទនេះអត់បានអីទេណ៎?

កុនៈ អត់ទេ! អត់ដឹងអីទេ ខ្ញុំនៅលើភ្នំហើយ ចុះមកអូរជីកដំបូង ពីលើភ្នំ មកលើអូរជីក (ស្តាប់ពុំបាន) ពីហ្នឹងមករហូត មិនដែរបានទេ បានតែពេលអាយើងចុះពីដំបូងមក ។ ដូចថាយើងមិនទាន់រកអីបាន ។ ដល់ពេល(ស្តាប់ពុំបាន) យើងចឹងទៅ ដល់ពេលយើងធ្វើស្រែ ធ្វើចម្ការយើងបានតិចតួចទៅអាចចេះរកស៊ីតិចតួចហើយ ក៏វាឈប់ទៅដាច់ទៅ តាប៊ីចេងនោះយើងមិនទិញ ហូបផង ។

បូលីៈ ចឹងអ្នកត្រពាំងប្រាសាទនេះអត់បានអីពីតាម៉ុកផង?

កុនៈ បានតែអ្នកគេនៅកៀកៗនេះ អ្នកដែលនៅដាច់ស្រយាល ថ្ងៃណាគេនឹកឃើញចឹង គេឲ្យទៅ ហើយថ្ងៃណានេះក៏អត់ទៅ ។

បូលីៈ បានន័យថាបានខ្លះដែរចឹង?

កុនៈ បាន! គ្រាន់ថាយើងនៅឆ្ងាយ វាមិនសូវបានជិតដល់ដូចគេ ។ គេអ្នកនៅជិតគេបានទៅ ។

បូលីៈ គេនោះ គេបាន១ខែ គេបានអង្ករម្នាក់៦០កំប៉ុង?

កុនៈ ចា៎ស!

បូលីៈ ហើយកូន បើប៉ុណ្ណេះអីម្នាក់សុទ្ធតែ៦០កំប៉ុងហើយនេះ ។ មឹងបានប៉ុណ្ណឹងអីដែរទេ កាលនោះ?

កុនៈ កូនខ្ញុំកើតមកសុទ្ធតែមិនទាន់ ស៊ីអង្កររបបទេ មិនទាន់ទេ របបអង្ករ របបអី ។ កើតមកធ្វើស្រែ ធ្វើស្រូវធើអីខ្លួនឯង ។

បូលីៈ ចុះតា០៥ គាត់អត់មានចែកអីឲ្យយើងទេ?

កុនៈ អត់!

បូលីៈ បើតា០៥ យើងគិតទៅយើងមេនៅនេះណា៎ មេនៅត្រពាំងប្រាសាទ ។

កុនៈ តា០៥ គាត់មេមែនតែ គាត់មិនដែលនៅជាប់ហ្នឹងប្រជាជនណា គាត់នៅតែអីក្នុង គាត់នៅតែក្នុងធ្វើសង្គ្រាម ។ គាត់នៅតែអីហ្នឹង ប៉ុន្តែគាត់មានទៅបន្ទុំយើងអីណា បើយើងធ្វើស្រែហូបបាន ក៏ហូបទៅ ស្រេចហ្នឹងយើង ។

បូលីៈ មានដែលឃើញតា ប៉ុល ពត គាត់ចុះមកទេ?

កុនៈ តាប៉ុល ពត ខ្ញុំអត់ដែរឃើញទេ មិនដែលទាល់តែសោះ ឮតែតាខៀវ ។

បូលីៈ តាខៀវ ដែលឃើញ?

កុនៈ តាខៀវឃើញ ។

បូលីៈ គាត់មកធ្វើអីគេ?

កុនៈ កាលនោះ ខ្ញុំឃើញនៅលើភ្នំ គាត់មកប្រជុំម្តងៗ ។

បូលីៈ ហ៎ូ! ឃើញនៅលើភ្នំទេណា៎?

កុនៈ ហ្នឹងឯង ។

បូលីៈ ពេលចុះមកនៅឯក្រោម មានដែរឃើញទេ?

កុនៈ អត់ដែលឃើញទេ ។

បូលីៈ ប៉ុនមកនៅក្រោមនេះមានដែលឃើញតាខៀវ តាប៉ុល ពតសោះតែម្តង?

កុនៈ អត់ដែរ ។

បូលីៈ ចុះតាម៉ុក មានដែរឃើញទេ?

កុនៈ តាម៉ុកនោះឃើញម្ដង ។

បូលីៈ ឃើញនៅឯណា?

កុនៈ ខ្ញុំឃើញ ខ្ញុំឡើងជិរុក-ហើយនៅលើភ្នំ ។

បូលីៈ យកអង្ករលើភ្នំ?

កុនៈ ចា៎ស!

បូលីៈ នៅឃ្លាំងកណ្ដាលអី?

កុនៈ នៅឃ្លាំងដាំនោះ ។

បូលីៈ ឃ្លាំងដាំយើង?

កុនៈ ចា៎ស! មកជួបគាត់នៅកន្លែងឃ្លាំងនោះ ។

បូលីៈ បានជួបគាត់មាននិយាយលេងជាមួយគាត់ទេ កាលហ្នឹង?

កុនៈ អត់!

បូលីៈ ដែលតែឃើញពីចម្ងាយទេ?

កុនៈ ដែរ ។

បូលីៈ គាត់ជិះអីគេកាលហ្នឹង?

កុនៈ ឡានធំគេ ។

បូលីៈ មីងយល់តាម៉ុក យ៉ាងម៉េចដែរ មនុស្សគាត់ កាច ឬក៏ស្លូត?

កុនៈ កាចដែរ! មិនស្លូតប៉ុន្មានទេ បើថាគាត់ឲ្យអីពីណាគេ បើមិនឆាប់ដើរចេញទេ គាត់ដក វិញ ផលូវ ។

បូលីៈ ដឹង ឮសួរគេនិយាយចឹងដែរតា ឲ្យហើយឆាប់ដើរចេញ ។ តាមិនដើរចេញ យកវិញផលូវ ហើយ ។

កុនៈ តាមិនដើរចេញ យកវិញឲ្យអ្នកផ្សេង ។

បូលីៈ សព្វថ្ងៃគឺថារស់នៅសមរម្យទេ ឬខ្វះខាតដែររាល់ថ្ងៃ?

កុនៈ ខ្វះខាតដែរសព្វថ្ងៃ មិនមានទុកដាក់សល់អីទេ ។

បូលីៈ ចំណូលរបស់យើង បានមកពីអីខ្លះ?

កុនៈ  គ្មានអីធ្វើផង មានតែធ្វើស្រែ ។ ធ្វើតែស្រែបានតែហូបទៅ នៅរាល់ថ្ងៃបើនិយាយរួមប្រាក់ចំណូល រាល់ថ្ងៃបានតែប្រាក់ខែឪវាហ្នឹងទេ ។

បូលីៈ  បាន១ខែប៉ុន្មាន?

កុនៈ  ១ខែ ជាង១០ម៉ឺន ។

បូលីៈ  ជាង១០ម៉ឺន ។

កុនៈ  ហើយប្រពន្ធកូនទៅរកអីបាន ។

បូលីៈ  ចុះដីស្រែ ប៉ុន្មានហិចតា?

កុនៈ  ធ្វើបាន២ហាត់ ។

បូលីៈ  ២ហាត់ដែរណ៎ ។ គ្រប់ទេហូបមួយឆ្នាំៗ?

កុនៈ  មិនគ្រប់ទេ ។

បូលីៈ  ចុះដំឡូង?

កុនៈ  ដំឡូងប្រហែលប៉ុន្មាន ២រ៉ៃហ្នឹង ។វាខ្វះដើមផង អត់បេះ ។

បូលីៈ  ២រ៉ៃហ្នឹងប៉ុន្មាន?

កុនៈ  ២រ៉ៃហ្នឹងបើគិតជាម៉ែត្រ ៨០ម៉ែត្រ ។

បូលីៈ  លក់បាន១គីឡូប៉ុន្មាន?

កុនៈ  អត់ទាន់ដឹងផង ។

បូលីៈ  គាស់?

កុនៈ  គាស់ហើយ ប៉ុន្តែមិនទាន់ដឹងតម្លៃ ឮតែបរចាមរាមថា១គីឡូ៧០០ ។

បូលីៈ  ដូចស្បូវដែរ ។ ស្បូវលក់ដែរ?

កុនៈ  គេបេះតែឲ្យក្រងតាមតែចិត្តខ្ញុំចង់ដែរ ។

បូលីៈ  ពីណាគេឲ្យក្រង?

កុនៈ  យកទៅលក់ឯណា ក្នុងភូមយើងគេកម្ម៉ង់ឲ្យយើង ក្រងទៅគ្រាន់តែក្រង មិនទាន់ផងមកដឹកយកអស់ហើយ ។

បូលីៈ  គេទិញយើង ឬក៏គេយក?

កុនៈ  គេទិញ ។ ប៉ុន្តែខ្ញុំហត់ពេក ខ្ញុំធ្វើតែ១០០ក្រប ។

បូលីៈ  ហើយយើងក្រងហ្នឹង ឬស្សី ។ ខ្ញុំសំនេះសំណាលលេងជាមួយមីងតែប៉ុណ្ណឹងទៅ ។

«ចប់»